ការពិត

# ការការពារការឆ្លងមេរោគ HIV៖ តើមេរោគ HIV ឆ្លងដោយរបៀបណា?



Khmer | ខ្មែរ

## តើមេរោគ HIV (វីរុសបង្កឱ្យកើតជំងឺអេដស៍) ឆ្លងដោយរបៀបណា?

មេរោគ HIV អាចឆ្លង នៅពេលសារធាតុរាវនៅក្នុងរាងកាយរបស់មនុស្សម្នាក់ដែលមានផ្ទុកមេរោគ HIV គ្រប់គ្រាន់ ចម្លងទៅក្នុងរាងកាយរបស់មនុស្សម្នាក់ទៀត។

សារធាតុរាវពីរាងកាយដែលអាចផ្ទុកមេរោគ HIV គ្រប់គ្រាន់គឺ៖

- ឈាម
- ទឹកកាម (និងមុនចេញទឹកកាម)
- ទឹករំអិលទ្វារមាស
- ទឹកដោះម្តាយ។

សារធាតុរាវពីរាងកាយដូចជាទឹកមាត់ ញើស និងទឹករំអិលច្រមុះ មិនមានផ្ទុកមេរោគ HIV គ្រប់គ្រាន់ដើម្បីចម្លងវីរុសនោះទេ។ នេះមានន័យថា **មេរោគ HIV មិនអាចចម្លងបាន**តាមរយៈការទំនាក់ទំនងប្រចាំថ្ងៃដូចជាក្អក កណ្តាស់ ឱប ថើប ឬការប្រើប្រាស់ឧបករណ៍រួមគ្នានោះទេ។ វាក៏មិនអាចចម្លងបានតាមរយៈមូសខាំ ឬសត្វខាំនោះដែរ។

សកម្មភាពនានាដែលមានហានិភ័យនៃការចម្លងមេរោគ HIV គឺ៖

- ការរួមភេទតាមរន្ធគូថ/ទ្វារមាស
- ការមានផ្ទៃពោះ ការសម្រាលកូន និងការបំបៅដោះកូន
- ការប្រើម្ជុលរួមគ្នាសម្រាប់ប្រើប្រាស់គ្រឿងញៀន ចាក់សាក់ ឬចោះស្បែក

## តើអ្វីជាចំនួនវីរុស ហើយតើវាប៉ះពាល់ដល់ការឆ្លងមេរោគ HIV ដោយរបៀបណា?

**ចំនួនវីរុស** គឺជាបរិមាណនៃវីរុស HIV នៅក្នុងខ្លួនរបស់អ្នក។ ការមានចំនួនវីរុសកាន់តែខ្ពស់ ឱកាសនៃការចម្លងមេរោគ HIV ក៏កាន់តែខ្ពស់ដែរ។ បើគ្មានការព្យាបាលទេ អ្នកមានមេរោគ HIV ជាធម្មតាមានចំនួនវីរុសច្រើន។ នេះមានន័យថា ឈាម ទឹកកាម ទឹករំអិលទ្វារមាស និងទឹកដោះម្តាយ អាចមានផ្ទុកមេរោគ HIV គ្រប់គ្រាន់ដើម្បីចម្លងវីរុស HIV។

ការព្យាបាលមេរោគ HIV ទំនើបគឺល្អខ្លាំងណាស់ ក្នុងការធ្វើឱ្យអ្នកមានសុខភាពល្អ និងបញ្ឈប់ការចម្លងមេរោគ HIV។ ការព្យាបាលមេរោគ HIV កាត់បន្ថយចំនួនវីរុសរបស់អ្នក។ **ការបង្ក្រាបមេរោគ** កើតឡើងនៅពេលដែលបរិមាណមេរោគ HIV នៅក្នុងខ្លួនមានកម្រិតទាប រហូតដល់វាមិនអាចចម្លងទៅមនុស្សម្នាក់ទៀតតាមរយៈការរួមភេទបាន។

ការស្រាវជ្រាវផ្នែកវេជ្ជសាស្ត្រជាច្រើនឆ្នាំបានបង្ហាញថាអ្នកផ្ទុកមេរោគ HIV ដែល **មានមេរោគត្រូវបានបង្ក្រាប** មិនអាចចម្លងមេរោគ HIV ទៅដៃគូរួមភេទរបស់ពួកគេបានទេ។ នេះមានន័យថា ប្រសិនបើអ្នកបានរក្សាចំនួនវីរុសក្រោម 200/ml យ៉ាងហោចណាស់ប្រាំមួយខែ ហើយបន្តលេបថ្នាំព្យាបាល (ដូចដែលបានណែនាំដោយវេជ្ជបណ្ឌិតរបស់អ្នក) វាគ្មានហានិភ័យក្នុងការចម្លងមេរោគ HIV ទៅដៃគូរួមភេទនោះទេ។

ជួនកាលគេហៅការបង្ក្រាបមេរោគថា **ចំនួនវីរុសដែលមិនអាចរកឃើញ**។ នេះជាហេតុផលនៃពាក្យស្លោកដែលគេនិយមហៅថា *Undetectable (មិនអាចរកឃើញ)* = *Untransmittable (មិនអាចចម្លងបាន) ឬ / U=U*។

ភ័ស្តុតាងវិទ្យាសាស្ត្របានបង្ហាញថា **ចំនួនមេរោគក្រោម 200c/ml មិនគ្រប់គ្រាន់ដើម្បីចម្លងមេរោគ HIV** ទេ។

## ចំនួនវីរុស និងការឆ្លងតាមការរួមភេទ

**ចំនួនវីរុសច្រើន**
*ហានិភ័យខ្ពស់នៃការចម្លងមេរោគវីរុស*

**ចំនួនវីរុសទាប**
*ហានិភ័យនៃការចម្លងមេរោគវីរុស*

**មេរោគត្រូវបានបង្ក្រាប/ មិនអាចរកឃើញ <200c/ml**
*គ្មានហានិភ័យនៃការចម្លងមេរោគវីរុស*



# តើត្រូវការពារការចម្លងមេរោគ HIV ដូចម្តេច?

*ការការពារការឆ្លងតាមការរួមភេទ*

មេរោគ HIV អាចឆ្លងបាន ប្រសិនបើដៃគូណាម្នាក់មានមេរោគ HIV។ ទោះយ៉ាងណាក៏ដោយ មានវិធីដ៏មានប្រសិទ្ធភាពខ្ពស់មួយចំនួនដែលអ្នកអាចការពារការចម្លងមេរោគ HIV ទៅកាន់ដៃគូរួមភេទរបស់អ្នក។

*ការព្យាបាលក៏ដូចជាការការពារ និង U=U*

ប្រសិនបើអ្នកមានផ្ទុកមេរោគ HIV ហើយមានផ្ទុកមេរោគដែលបានបង្ក្រាប (មិនអាចរកឃើញ) អ្នកមិនអាចចម្លងមេរោគ HIV ទៅដៃគូរួមភេទរបស់អ្នកបានទេ។ នេះត្រូវបានគេស្គាល់ថា ការព្យាបាលជាការការពារ ឬ មិនអាចរកឃើញ = មិនអាចចម្លងបាន។

*ស្រោមអនាម័យ និងទឹករំអិល*

ប្រសិនបើមេរោគរបស់អ្នកមិនបានបង្ក្រាប ឬមិនប្រាកដពីស្ថានភាពដៃគូរបស់អ្នកទេ អ្នកអាចការពារការចម្លងមេរោគ HIV ដោយប្រើស្រោមអនាម័យនៅពេលរួមភេទតាមទ្វារមាស និងរន្ធគូថ។ ស្រោមអនាម័យកាត់បន្ថយហានិភ័យនៃការចម្លងមេរោគ HIV យ៉ាងច្រើន។ សូមចងចាំត្រូវប្រើប្រេងរំអិលដែលមានជាតិទឹកដើម្បីការពារការធ្លុះធ្លាយ។

*PrEP*

វិធីការពារមុនពេលប្រឈមនឹងការឆ្លង ឬ PrEP គឺជាថ្នាំព្យាបាលដែលមនុស្សគ្មានផ្ទុកមេរោគ HIV លេបដើម្បីការពារការឆ្លងមេរោគ HIV។ វាមានប្រសិទ្ធភាពខ្ពស់នៅពេលបានលេបជាប់លាប់តាមវេជ្ជបញ្ជា។ សូមពិភាក្សាជាមួយបុគ្គលិក ឬអ្នកជំនាញថែទាំសុខភាពថាតើ PrEP អាចសមស្របសម្រាប់ដៃគូដែលគ្មានផ្ទុកមេរោគ HIV របស់អ្នកឬអត់។

## *ចុះចំពោះការឆ្លងក្នុងអំឡុងពេលមានផ្ទៃពោះ ការសម្រាលកូន និងការបំបៅដោះកូន?*

នៅពេលអ្នកកំពុងទទួលការព្យាបាល ហើយមានផ្ទុកមេរោគដែលបានបង្ក្រាប (មិនអាចរកឃើញ) ក្នុងអំឡុងពេលមានផ្ទៃពោះទាំងស្រុង ហានិភ័យនៃទារកកើតមកមានមេរោគ HIV គឺទាបខ្លាំងណាស់ (តិចជាង 1 ភាគរយ)។ ការព្យាបាលមេរោគ HIV ភាគច្រើនមានសុវត្ថិភាពអំឡុងពេលមានផ្ទៃពោះ។ សូមពិភាក្សាជាមួយវេជ្ជបណ្ឌិតព្យាបាលមេរោគ HIV របស់អ្នក ប្រសិនបើអ្នកគិតចង់មានផ្ទៃពោះ  ឬកំពុងមានផ្ទៃពោះ។

ការស្រាវជ្រាវថ្មីៗបានបង្ហាញថា ប្រសិនបើអ្នកកំពុងទទួលការព្យាបាលដោយប្រើថ្នាំប្រឆាំងមេរោគ HIV ហើយមានផ្ទុកមេរោគដែលបានបង្ក្រាបហានិភ័យនៃការចម្លងមេរោគ HIV តាមរយៈទឹកដោះម្ដាយគឺទាបណាស់។ ខណៈដែលការណែនាំផ្នែកវេជ្ជសាស្ត្រក្នុងប្រទេសអូស្ត្រាលីនាពេលបច្ចុប្បន្ន គឺការបំបៅដោយម្សៅទឹកដោះដើម្បីការពារឱកាសនៃការឆ្លងណាមួយក្ដី អ្នកអាចធ្វើការសម្រេចចិត្ត ដើម្បីបំបៅដោះកូន។

សូមចូលទៅកាន់ Positive Women Victoria (ស្ត្រីវិជ្ជមានរដ្ឋវិចថូរៀ) សម្រាប់ព័ត៌មានបន្ថែមអំពីការបំបៅដោះកូន ឬចូលទៅកាន់ *ព័ត៌មានបន្ថែម* កូដ QR នៅចុងបញ្ចប់នៃអត្ថបទនេះ។

## *តើវានៅតែមានហានិភ័យក្នុងការប្រើប្រាស់ម្ជុល ឬវត្ថុមុតស្រួចផ្សេងទៀតរួមគ្នាឬទេ?*

មេរោគ HIV អាចម្លងតាមរយៈការប្រើម្ជុលរួមគ្នាដើម្បីចាក់ថ្នាំអរម៉ូន ឬឱសថ និងឧបករណ៍ចោះស្បែក ឬចាក់សាក់។ ការបង្ក្រាបមេរោគកាត់បន្ថយហានិភ័យនៃការចម្លងមេរោគ HIV បានយ៉ាងច្រើន នៅពេលប្រើឧបករណ៍ចាក់ ចាក់សាក់ ឬចោះស្បែករួមគ្នាប៉ុន្តែយើងមិនដឹងថាកាត់បន្ថយបានប៉ុន្មាននោះទេ។

គេណែនាំឱ្យប្រើម្ជុល និងសឺរ៉ាំងបានសម្លាប់មេរោគរួច គ្រប់ពេលដើម្បីការពារការចម្លងមេរោគ HIV និងវីរុសផ្សេងៗក្នុងឈាម។ Needle and Syringe Programs (NSPs) ផ្ដល់ឧបករណ៍ចាក់ដែលបានសម្លាប់មេរោគរួច និងសេវាបោះចោលដោយឥតគិតថ្លៃសម្រាប់មនុស្សគ្រប់គ្នានៅរដ្ឋវិចថូរៀ។

# ប្រសិនបើនរណាម្នាក់ត្រូវបានប៉ះពាល់មេរោគ HIV តើពួកគេគួរធ្វើអ្វីខ្លះ?

ប្រសិនបើនរណាម្នាក់ត្រូវបានប៉ះពាល់មេរោគ HIV ពួកគេគួរស្វែងរកឱសថដែលមានឈ្មោះថា ការការពារមេរោគអេដស៏ក្រោយការប៉ះពាល់នឹងមេរោគនេះ ឬហៅថា PEP។ PEP កាត់បន្ថយឱកាសនៃការឆ្លងមេរោគ HIV។ វាមានសារៈសំខាន់ណាស់ដែលត្រូវចាប់ផ្តើមពិសាថ្នាំ PEP ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន និយាយរួមក្នុងអំឡុងពេល2ម៉ោងដំបូង និងមិនឱ្យលើសពី72ម៉ោង (3ថ្ងៃ) បន្ទាប់ពីបានប៉ះពាល់មេរោគនេះ។

ដើម្បីស្វែងរកកន្លែងដែលនៅជិតអ្នកបំផុតដើម្បីទទួលបានឪសថ PEP សូមទូរសព្ទបណ្តាញទូរសព្ទលេខ **1800 889 887** ឬចូលទៅកាន់គេហទំព័រ **www.getpep.info**

## សម្រាប់ព័ត៌មានបន្ថែម

living positive victoria

ViiV Healthcare